# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

សំណុំរឿងព្រហ្មទណ្ឌ
លេខ ៣១១
ចុះថ្ងៃទី០៧-០៤-២០១៦

សាលដីកា
លេខ : ២១ ក្រIV "វ"
ចុះថ្ងៃទី ២៩-០៦-២០១៧

## តាងនាមប្រជារាស្ត្រខ្មែរ

## សាលាឧទ្ធរណ៍ភ្នំពេញ

បង្កើតឡើងតាមច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ដែលប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ : នស/រកម/០៧១៤/០១៥ ចុះថ្ងៃទី១៦-០៧-២០១៤ បានបើកសវនាការជាសាធារណៈ នៅសាលាឧទ្ធរណ៍ នាថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១៧ ដោយមាន ៖

**<u>សមាសភាពក្រុមប្រឹក្សា</u>**

លោក [redacted] ជាប្រធានក្រុមប្រឹក្សា

លោក [redacted] ជាចៅក្រមប្រឹក្សា

លោក [redacted] ជាចៅក្រមប្រឹក្សា

**<u>តំណាងមហាអយ្យការ</u>**

លោកស្រី [redacted] ព្រះរាជអាជ្ញា

**<u>ក្រឡាបញ្ជី</u>**

លោក [redacted]

ដើម្បីជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍នៃសំណុំរឿងព្រហ្មទណ្ឌលេខ ៣១១ ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០១៦ ដែលមាន ៖

- ជនជាប់ចោទឈ្មោះ[redacted] ភេទប្រុស អាយុ៥៨ឆ្នាំ សញ្ជាតិខ្មែរ មុខរបរកសិករ មានទីកន្លែងកំណើត នៅភូមិគោកញ ឃុំព្រៃស្វឹក ស្រុកទ្រាំង ខេត្តតាកែវ និងទីលំនៅបច្ចុប្បន្ននៅភូមិក្រពើហា សង្កាត់ព្រែកឬស្សី ក្រុងតាខ្មៅ ខេត្តកណ្តាល ប្រពន្ធឈ្មោះ[redacted]" មានកូន ៦នាក់ ឪពុកឈ្មោះ[redacted]" ម្តាយឈ្មោះ[redacted]" ជាទីតិជន ទោសពីមុនគ្មាន ។ (ឃុំខ្លួនថ្ងៃទី២២-០៧-២០១៥)

ត្រូវឱ្យដាក់នៅក្រោមការពិនិត្យពីបទ៖ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចភូមិព្រែកសំរោង៣ សង្កាត់តាខ្មៅ ក្រុងតាខ្មៅ ខេត្តកណ្តាល កាលពី ថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០១៥ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ៤០ នៃច្បាប់ស្តីការត្រួតពិនិត្យគ្រឿងញៀន ។

មានលោកស្រី[redacted]ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ។

**<u>៦រឿងហេតុមានដូចតទៅ</u>**





Scanned by CamScanner

កាលពីថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០១៥ វេលាម៉ោង ១០ និង៣០នាទី ព្រឹក កម្លាំងកងរាជអាវុធហត្ថក្រុងតាខ្មៅ បានប្រតិបត្តិការចេញល្បាតចល័តតាមដងផ្លូវក្នុងភូមិសាស្ត្រក៏ប្រទះឃើញជនសង្ស័យឈ្មោះ [redacted] កំពុងធ្វើដំណើរលើដងផ្លូវលេខ ២១ បេ ក្នុងភូមិព្រែកសំរោង៣ សង្កាត់តាខ្មៅ ក្រុងតាខ្មៅ ខេត្តកណ្ដាល ដោយមានការសង្ស័យក៏ហៅឈប់សួរនាំ ហើយរកឃើញថ្នាំញៀនប្រភេទម៉ាទឹកកកចំនួន ១៣កញ្ចប់តូច ដែលនៅជាប់លើខ្លួនជនសង្ស័យនោះ បន្ទាប់មកសមត្ថកិច្ចកងរាជអាវុធហត្ថក៏បានធ្វើការឃាត់ខ្លួនជនសង្ស័យឈ្មោ[redacted]ួនមកតុលាការ។

**បានឃើញ** សាលក្រមព្រហ្មទណ្ឌលេខ**២៩ "ខ"** ចុះថ្ងៃទី២៨-០៣-២០១៦ របស់សាលាដំបូងខេត្តកណ្ដាល ដែលបានសម្រេចសេចក្ដីដូចខាងក្រោម៖

១-ផ្ដន្ទាទោសលើឈ្មោះ[redacted]ដាក់ពន្ធនាគារ ២ (ពីរ)ឆ្នាំ ពីបទ **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុចភូមិព្រែកសំរោង៣ សង្កាត់តាខ្មៅ ក្រុងតាខ្មៅ ខេត្តកណ្ដាល កាលពីថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០១៥ តាមមាត្រា ៤០ នៃច្បាប់ស្ដីការត្រួតពិនិត្យគ្រឿងញៀន ។

២-វត្ថុតាងដកហូតបានមាន ថ្នាំញៀនប្រភេទមេតាំហ្វេតាមីនចំនួន ១៣ កញ្ចប់តូច មានទម្ងន់ស្មើនឹង ១.២៨ (មួយក្បៀសម្ភៃប្រាំបី) ក្រាម និងទូរស័ព្ទពីរគ្រឿង ម៉ាកណូគា សេរីចាស់ ពណ៌ខ្មៅ ក្រមខ្មៅ ត្រូវរឹបអូស ។

៣-សាលក្រមនេះជំនុំជម្រះ និងប្រកាសជាសាធារណៈនៅថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៦ ចំពោះមុខជនជាប់ចោទ ។

ទុកសិទ្ធិប្ដឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

**បានឃើញ** ពាក្យបណ្ដឹងឧទ្ធរណ៍ចុះថ្ងៃទី៣០-០៣-២០១៦ របស់លោក **ព្រះរាជអាជ្ញាអមសាលាដំបូងខេត្តកណ្ដាល** ប្ដឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ**២៩ "ខ"** ចុះថ្ងៃទី២៨-០៣-២០១៦ របស់សាលាដំបូងខេត្តកណ្ដាល ត្រង់ចំណុចនៃសេចក្ដីសម្រេចទាំងមូល ដោយសារការផ្ដន្ទាទោសជនជាប់ចោទទាបពេក។

**<u>នាពេលសវនាការ</u>**

- ប្រធានក្រុមប្រឹក្សាអានរបាយការណ៍សង្ខេបរឿងក្ដី

-ជនជាប់ចោទឈ្មោះ[redacted]បានឆ្លើយថា៖ ខ្លួនបានទិញថ្នាំញៀនពីគេចំនួន១៣កញ្ចប់មែន ស្នើសុំតំកល់សាលក្រមសាលាដំបូងខេត្តកណ្ដាលដដែល។

-តំណាងមហាអយ្យការសន្និដ្ឋាន ៖ ចំពោះការផ្ដន្ទាទោសដាក់ពន្ធនាគារពីរឆ្នាំ គឺមានលក្ខណៈត្រឹមត្រូវហើយ សុំក្រុមប្រឹក្សាសម្រេចសេចក្ដីតាមការយល់ឃើញខាងលើ។

-មេធាវី [redacted]ថ្លែងថា៖ សុំឱ្យក្រុមប្រឹក្សាតម្កល់សាលក្រមសាលាដំបូងទុកជាបានការដដែល។

- ក្រោយពីបានអំណានស្ដាប់ចម្លើយរបស់ជនជាប់ចោទ
- ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិ



Scanned by CamScanner

- ក្រោយពីបានពិចារណាលើគ្រប់កស្តុតាង និងឯកសារផ្សេងៗ

- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

<u>សំអាងហេតុ</u>

យល់ឃើញថា

១- ពាក្យបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី៣០-០៣-២០១៦ របស់លោក ព្រះរាជអាជ្ញាអមសាលាដំបូងខេត្តកណ្តាល ប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ២៩ "ខ" ចុះថ្ងៃទី២៨-០៣-២០១៦ របស់សាលាដំបូងខេត្តកណ្តាល ធ្វើឡើងក្នុងកំណត់ច្បាប់ យោងតាមមាត្រា ៣៨១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។ សាលាឧទ្ធរណ៍ទទួលជំនុំជម្រះបាន ។

២-នាពេលសវនាការសាលាឧទ្ធរណ៍ជនជាប់ចោទឈ្មោ[redacted]បានឆ្លើយថា ខ្លួនបានទិញថ្នាំញៀនពីគេចំនួន១៣កញ្ចប់មែន ដើម្បីយកទៅលក់បន្ត ស្នើសុំតំកល់សាលក្រមសាលាដំបូងខេត្តកណ្តាលដដែល។

ក្រុមប្រឹក្សាយល់ឃើញថា ក្នុងការដែលជនជាប់ចោទស្នើសុំតម្កល់សាលក្រមរបស់សាលាដំបូងខេត្តកណ្តាល ជាការត្រឹមត្រូវហើយ ដោយហេតុថា អំពើរបស់ជនជាប់ចោទ ពិតជាអំពើល្មើសដែលមានចែងក្នុងមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ប្រាកដមែន។ ម្យ៉ាងវិញទៀត ជនជាប់ចោទបានសារភាពពីទោសកំហុសរបស់ខ្លួន ហើយតាមរយៈកំណត់ហេតុចាប់យកវត្ថុតាងលេខ៤៥/២០១៥ របស់មូលដ្ឋានកងរាជអាវុធហត្ថក្រុងតាខ្មៅ ឃើញថា ចំនួនគ្រឿងញៀន (ប្រភេទម៉ាទឹកកក) ដែលចាប់យក មានចំនួនត្រឹមតែ១៣ កញ្ចប់ ស្មើនឹង ១.២៨ ក្រាម តែប៉ុណ្ណោះ(ឯកសារលេខ១/១២)។

ដោយយោងតាមមាត្រា ៤០ នេះ ឃើញថា ជនដែលបានទិញ រក្សាទុក ឬប្រើប្រាស់គ្រឿងញៀន ត្រូវដាក់ពន្ធនាគារពី ១ឆ្នាំ ដល់ ៥ឆ្នាំ។ ដូចនេះ ក្រុមប្រឹក្សាយល់ឃើញថា ការផ្តន្ទាទោសជនជាប់ចោទរយៈពេល ២(ពីរ)ឆ្នាំ នេះគឺ មានភាពត្រឹមត្រូវ និងសមស្របហើយ។

៣-តំណាងមហាអយ្យការសន្និដ្ឋាន ចំពោះការផ្តន្ទាទោសដាក់ពន្ធនាគារពីរឆ្នាំ គឺមានលក្ខណៈត្រឹមត្រូវហើយ សុំក្រុមប្រឹក្សាសម្រេចសេចក្តីតាមការយល់ឃើញខាងលើ។

ក្រុមប្រឹក្សាយល់ឃើញថា សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ មានលក្ខណៈត្រឹមត្រូវហើយ គប្បីក្រុមប្រឹក្សាពិចារណា និងសម្រេចតាមការយល់ឃើញខាងលើ។

៤-មេធាវី[redacted]ានសន្និដ្ឋានថា ស្នើសុំឲ្យក្រុមប្រឹក្សាធ្វើការតម្កល់សាលក្រមសាលាដំបូងទុកជាបានការដដែល។

ក្រុមប្រឹក្សាយល់ឃើញថា សេចក្តីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ មានលក្ខណៈត្រឹមត្រូវហើយ គប្បីក្រុមប្រឹក្សាពិចារណា និងសម្រេចតាមការយល់ឃើញខាងលើ។

៥-សាលក្រមព្រហ្មទណ្ឌលេខ ២៩ "ខ" ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៦ របស់សាលាដំបូងខេត្តកណ្តាល ដែលបានសម្រេចមកនេះ មានលក្ខណៈត្រឹមត្រូវហើយ គប្បីក្រុមប្រឹក្សាសម្រេចតម្កល់សាលក្រមទុកជាបានការដដែល ។



Scanned by CamScanner

**<u>ហេតុដូច្នេះ</u>**

**<u>ទីនិច្ឆ័យសេចក្តី</u>**

១-ពាក្យបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី៣០-០៣-២០១៦ របស់លោក ព្រះរាជអាជ្ញាអមសាលាដំបូងខេត្តកណ្តាល ធ្វើឡើងត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយខាស់ទីឯគតិច្បាប់។

២-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ២៩ "ខ" ចុះថ្ងៃទី២៨-០៣-២០១៦ របស់សាលាដំបូងខេត្តកណ្តាល ទុកជាបានការដដែល ។

សាលដីកានេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១៧ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ និងប្រកាសជាសាធារណៈនៅថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៧ ។

ទុកសិទ្ធិប្តឹងសាទុក្ខក្នុងកំណត់ច្បាប់ ។

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សា |
|---|---|---|
| ហត្ថលេខា [redacted] | ហត្ថលេខា [redacted] | ហត្ថលេ[redacted] |

---

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

បានឃើញ

ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

[redacted]

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែកក្កដា ឆ្នាំ២០១៧

ក្រឡាបញ្ជី

[redacted]



Scanned by CamScanner